**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ៧៧៦១ សជណ. កសក

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទទួលពាក្យបណ្ដឹងតាមរយៈគេហទំព័រ របស់អគ្គាធិការដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានកិត្តិយសសូមជូនដំណឹងដល់គ្រប់អង្គភាព មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត មន្ត្រីរាជការទូទៅក្រោមឱវាទក្រសួង និងសាធារណជនទាំងអស់មេត្តាជ្រាបថា អគ្គាធិការដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងដាក់ឱ្យដំណើរការជាផ្លូវការ នូវប្រព័ន្ធទទួលពាក្យបណ្ដឹងតាមរយៈគេហទំព័ររបស់អគ្គាធិការដ្ឋាន(GI.MAFF.GOV.KH) គ្រប់ពេលវេលាចាប់ពីពេលនេះតទៅ ដើម្បីទទួលពាក្យបណ្ដឹងញត្តិតវ៉ា ឬបណ្ដឹងបរិហារទាំងឡាយរបស់បណ្ដាអង្គភាព មន្ត្រីរាជការទូទៅក្រោមឱវាទក្រសួង និងសាធារណជនដែលទទួលនូវបញ្ហាបាតុភាពនានា ឬភាពមិនប្រក្រតីជាយថាហេតុ ដែលកើតមានឡើងពាក់ព័ន្ធនឹងការងារដឹកនាំគ្រប់គ្រងរបស់អង្គភាពនានាក្រោមឱវាទក្រសួង។

ទទួលបានសេចក្ដីជូនដំណឹងនេះ ខ្ញុំសង្ឃឹមថាគ្រប់អង្គភាព មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត មន្ត្រីរាជការទូទៅក្រោមឱវាទក្រសួង និងសាធារណជនទាំងអស់មេត្តាចូលរួមសហការអនុវត្តប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។

ថ្ងៃ ៣ ១៥ កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០២០
**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន៖**
-គ្រប់អង្គភាពក្រោមឱវាទក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-គ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត
" ដើម្បីជ្រាបជាព័ត៌មាន "
-ឯកសារ កាលប្បវត្តិ